# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៤៥០.កយ.រប-០៦

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## <u>ជម្រាបមក</u>

**លោកប្រធានតុលាការខេត្ត-ក្រុង**

**<u>កម្មវត្ថុ:</u>** អំពីការប្រើប្រាស់ទម្រង់ ដីកាការពារ ដែលមានបញ្ញត្តិនៅក្នុងច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។

**<u>យោង:</u>** ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។

-លិខិតខ ៦៣៣.កកន ចុះថ្ងៃទី២៣-១២-០៥ របស់ក្រសួងកិច្ចការនារី ។

ខ្ញុំសូមជម្រាបអស់លោក-លោកស្រីថា ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះដែលជួសភាបានអនុម័ត កាលពីថ្ងៃទី១៦-០៩-២០០៥ ហើយបានចូលជាធរមាននោះហើយមានបញ្ញាត្តិមួយចំនួនបានចែងអំពីវិធានការ និងសមត្ថកិច្ចរបស់តុលាការខេត្ត-ក្រុង ក្នុងការចេញដីកាការពារ ។

ដោយបច្ចុប្បន្ន យើងពុំទាន់មានទម្រង់សម្រាប់ឱ្យប្រើប្រាស់ដីកាការពារនេះ ជាផ្លូវការនៅឡើយ អាស្រ័យហេតុនេះ សូមលោក-លោកស្រី នៃតុលាការខេត្ត-ក្រុង ទាំងអស់ប្រើប្រាស់នូវទម្រង់ ដីកាការពាដែលមានបញ្ញត្តិនៅក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ នេះតាមទម្រង់នៃ ដីកាសម្រេចកិច្ចការប្រញាប់ ដែលកំពុងប្រើប្រាស់ក្នុងពេលបច្ចុប្បន្ននេះ ជាបណ្តោះអាសន្នសិន ទម្រាំក្រសួងយុត្តិធម៌រៀបចំរួចរាល់នូវទម្រង់ដីកាការពារ សម្រាប់ឱ្យប្រើប្រាស់ជាផ្លូវការ នាពេលខាងមុខនេះ ។

ក្រសួងសង្ឃឹមថា អស់លោក-លោកស្រីប្រធានតុលាការខេត្ត-ក្រុង ទាំងអស់នឹងយកចិត្តទុកដាក់អនុវត្តតាមការណែនាំនេះ ឱ្យបានល្អប្រសើរ និងមានប្រសិទ្ធិភាពខ្ពស់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៦

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍានា**

<u>ចម្លងជូន</u>

-តុលាការ មហាអយ្យការ អយ្យការ គ្រប់ជាន់ថ្នាក់
ដើម្បីជ្រាប និង អនុវត្ត
-ក្រសួងកិច្ចការនារី
ដើម្បីជ្រាប
-ឯកសារ -កាលប្បវត្តិ